**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ១១៧០ អយក.ប្រក

# ប្រកាស

ស្តីពី ការប្តូរឈ្មោះសាលាបឋមសិក្សា ព្រែកឆឹង

មកជាសាលាបឋមសិក្សា សាការាម៉ូតូ ព្រែកឆឹង

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតរបស់គណៈកម្មការទ្រទ្រង់សាលា បុគ្គលិកសិក្សានៃសាលាបឋមសិក្សា **ព្រែកឆឹង** ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ដោយមានចំណារឯកភាពរបស់ប្រធានមន្ទីរអប់រំ យុវជន និង កីឡា **ខេត្ត កណ្តាល** ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

### ស ំ រេ ច

<u>ប្រការ១</u> : ប្តូរឈ្មោះសាលាបឋមសិក្សា **ព្រែកឆឹង** មកជា សាលាបឋមសិក្សា សាការាម៉ូតូ **ព្រែកឆឹង** វិញដែលមានទីតាំងស្ថិតនៅភូមិ ព្រែកឆឹង ឃុំ **ស៊ីធរ** ស្រុក **ខ្សាច់កណ្តាល** ខេត្ត **កណ្តាល** ចាប់ពីឆ្នាំសិក្សា ២០០៣-២០០៤ នេះតទៅ ។

**<u>ប្រការ២</u>** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ៣</u> : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កណ្តាល** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ខ្សាច់កណ្តាល** នាយកសាលាបឋមសិក្សា សាការាម៉ូតូ ព្រែកឆឹង មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **កណ្តាល**

**<u>"ដើម្បីជូនជ្រាបជាពត៌មាន"</u>**

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា បស